# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាថ្ងៃសុក្រពិសិដ្ឋនៅព្រះសហគមន៍សន្តីម៉ារីញញឹមចំការទៀន
# តាខ្មៅ ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២០
## ចូលនៅក្នុងភាពស្ងៀមស្ងាត់ដើម្បីទទួលជីវិតថ្មី

**អត្ថបទទី១៖ អេសាយ ៥២,១៣-៥៣,១២**

តាមពិត លោកបានរងទុក្ខវេទនាជំនួសយើង លោកទទួលយកការឈឺចាប់របស់យើង មកដាក់លើខ្លួនលោក។ រីឯយើងវិញ យើងស្មានថាព្រះជាម្ចាស់បានដាក់ទោសលោក ព្រះអង្គបានវាយ និងបន្ទាបបន្ថោកលោក។ អស ៥៣,៤

**អត្ថបទទី២៖ ហេប្រឺ ៤,១៤-១៦.៥,៧-៩**

ថ្វីដ្បិតតែព្រះអង្គជាព្រះបុត្រាក៏ដោយ ព្រះអង្គក៏បានរៀនស្ដាប់បង្គាប់ ដោយរងទុក្ខលំបាក។ បហ ៥,៨

**ដំណឹងល្អ៖ យ៉ូហាន ១៨,១-១៩,៤២**

ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ «ខ្ញុំបានប្រាប់អ្នករាល់គ្នាថា ខ្ញុំហ្នឹងហើយ បើអ្នករាល់គ្នាមករកខ្ញុំ ទុកឲ្យអ្នកទាំងនេះចេញទៅចុះ»។យហ ១៨,៨

បងប្អូនជាទីស្រឡាញ់!

ឲ្យយើងចាប់អារម្មណ៍អំពីព្រះបន្ទូលខ្លះៗ ថ្ងៃនេះជាថ្ងៃចុងក្រោយរបស់ព្រះយេស៊ូនៅលើផែនដីនេះ ព្រះយេស៊ូមានព្រះបន្ទូលទៅលោកពីឡាតថា "**ខ្ញុំកើតមក ហើយមកក្នុងលោកនេះ ដើម្បីសម្ដែងបញ្ជាក់អំពីសេចក្ដីពិត អ្នកណាកើតពីសេចក្ដីពិតអ្នកនោះនឹងស្ដាប់សម្លេងខ្ញុំ**"។ នៅលើឈើឆ្កាង ព្រះយេស៊ូមានព្រះបន្ទូលទៅលោកយ៉ូហានថា "**អ្នកអើយនេះហើយម្ដាយរបស់អ្នក**" និងមានព្រះបន្ទូលទៅព្រះនាងម៉ារីថា "**នេះហើយកូនរបស់អ្នក**"។ ពាក្យចុងក្រោយមុនព្រះអង្គផុតដង្ហើមគឺ "**ខ្ញុំបានបង្ហើយសព្វគ្រប់អស់ហើយ**" ទាំងអស់គ្នាគេនាំគ្នាមើលអ្នកដែលគេចាក់នៅលើឈើឆ្កាងនេះ។

ព្រះយេស៊ូបានរងទុក្ខលំបាកដោយលីឈើឆ្កាង ពីកន្លែងកាត់ក្ដីរហូតដល់លើភ្នំ ជាពេលវេលាចុងក្រោយរបស់ព្រះអង្គរស់នៅលើផែនដីនេះ នៅក្នុងការរងទុក្ខលំបាកយ៉ាងធ្ងន់ណាស់។ ទុក្ខលំបាកលើរូបកាយ ព្រោះត្រូវគេឆ្កាងដែលណែនាំឲ្យឈឺចាប់ដល់កំពូល ទុក្ខលំបាកនៅក្នុងផ្លូវវិញ្ញាណ ដោយសារព្រះអង្គនឹកឃើញដល់ក្រុមគ្រីស្តទូត ក្រុមសាវ័ក មិត្តសម្លាញ់ មហាជនដែលព្រះអង្គធ្លាប់ព្យាបាលគេ ទាំងអស់គ្នាបាត់ខ្លួនគ្មានសល់ម្នាក់។ ទុក្ខលំបាកថែមទៀត ដោយសារព្រះយេស៊ូជាព្រះបុត្រានៃព្រះជាអម្ចាស់ បីដូចជាព្រះបិតាបានបោះបង់ចោលព្រះបុត្រាតែម្ដង។ តាមពិត នៅលើឈើឆ្កាងនេះព្រះយេស៊ូបានផ្ដល់សក្ខីភាពចុងក្រោយបំផុតរបស់ព្រះអង្គ អំពីសេ

ចក្ដីពិត នៅលើឈើឆ្កាងព្រះយេស៊ូបានបង្ហាញសេចក្ដីពិតដ៏ជាក់ស្ដែង។ ពីម្សិលមិញព្រះយេស៊ូរួមជាមួយក្រុមគ្រីស្ដទូតកំពុងជប់លៀងរួមគ្នា ក្រុមគ្រីស្ដទូតមិនសូវយល់នៅពេលព្រះយេស៊ូយកនំប៉័ងនិងស្រា ហើយព្រះអង្គមានព្រះបន្ទូលថា "**នេះជារូបកាយរបស់ខ្ញុំ នេះជាលោហិតរបស់ខ្ញុំ**"។ យប់នេះ នៅលើឈើឆ្កាងព្រះបន្ទូលរបស់ព្រះយេស៊ូពោរពេញដោយអត្ថន័យដ៏ពេញលក្ខណៈ នៅពេលនោះគឺព្រះយេស៊ូបានប្រទានព្រះកាយ ព្រះយេស៊ូបានបូជាជីវិត ដើម្បីសង្គ្រោះមនុស្សលោក។

តាមពិត ព្រះយេស៊ូមិនចេះតែអួតខ្លួនគ្រប់ព្រះបន្ទូលរបស់ព្រះអង្គ ទៅជាសក្ខីភាព ទៅជាស្នាព្រះហស្ដដ៏ជាក់ស្ដែង នៅពេលព្រះអង្គមានព្រះបន្ទូលណាមួយព្រះអង្គអនុវត្តភ្លាម។ នៅក្នុងធម្មទេសនាដំបូងរបស់ព្រះយេស៊ូដែលថា ខ្ញុំយាងមកដើម្បីរំដោះអ្នកខ្វាក់ឲ្យគេមើលឃើញ អ្នកដែលជាប់ក្នុងមន្ទីរឃុំឃាំងឲ្យគេមានសេរីភាព ដើម្បីប្រកាសអំពីឆ្នាំមហាករុណាទិគុណដល់អ្នកក្រីក្រ។ ព្រះបន្ទូលនេះបានទៅជារូបរាងនៅពេលហ្នឹង អ្វីៗទាំងអស់ដែលព្រះយេស៊ូមានព្រះបន្ទូលព្រះអង្គបានធ្វើយ៉ាងជាក់ស្ដែង។ ថ្ងៃនេះយើងឃើញ នេះជាព្រះកាយរបស់ខ្ញុំ នេះជាព្រះលោហិតរបស់ខ្ញុំ នៅលើឈើឆ្កាងជារូបកាយនិងជាលោហិតរបស់ព្រះយេស៊ូដែលថ្វាយទៅព្រះជាម្ចាស់ ដើម្បីឲ្យយើងមានជីវិតអស់កល្បជានិច្ច។

នៅក្នុងព្រះបន្ទូលរបស់ព្រះយេស៊ូតាមសន្តយ៉ូហាន យើងបានឃើញព្រះនាងម៉ារីនិងសាវ័កដ៏ជាទីស្រឡាញ់របស់ព្រះអង្គដែលនៅក្បែរឈើឆ្កាង។ សម្រាប់យើង នៅពេលយើងមើលឃើញព្រះនាងម៉ារីនិងលោកយ៉ូហាន នេះជាសេចក្ដីសង្ឃឹមមួយយ៉ាងពិសេស សាវ័កបាត់អស់ហើយ គ្រីស្ដទូតបាត់អស់ហើយ អ្នកដែលព្រះអង្គធ្លាប់ព្យាបាលគេបាត់អស់ហើយ។ តាមរយៈលោកយ៉ូហាន ព្រះយេស៊ូបានប្រទានព្រះនាងម៉ារីដែលជាមាតារបស់ព្រះអង្គ ឲ្យធ្វើជាម្ដាយរបស់យើង។ ទោះបីព្រះយេស៊ូសោយទិវង្គតនៅលើឈើឆ្កាង ក៏យើងដឹងថាយើងមានព្រះនាងម៉ារីដែលមិនបានចោលព្រះយេស៊ូ ដែលណែនាំឲ្យយើងធ្វើដំណើរដើម្បីឆ្លងទុក្ខលំបាកដែលយើងជួបនៅក្នុងជីវិត ដើម្បីរកឃើញជីវិតរួមជាមួយព្រះយេស៊ូគ្រីស្ដ។

សប្ដាហ៍មុននៅអរិយក្សត្រ ខ្ញុំបានទូលអង្វរព្រះជាម្ចាស់តាមរយៈព្រះនាងម៉ារីសូមថែរក្សាប្រទេសកម្ពុជាយើង ថែរក្សាព្រះសហគមន៍របស់យើង ថែរក្សាគ្រួសារយើងនៅក្នុងពេលមានទុក្ខលំបាកនៃជំងឺកូវីដ១៩។ បន្តិចទៀត ទៅពេលខ្ញុំទៅថ្វាយបង្គំនិងគោរពព្រះឈើឆ្កាង ខ្ញុំនឹងយកពេលវេលាម្ដងទៀតរួមជាមួយព្រះនាងម៉ារីដែលនៅក្បែរព្រះឈើឆ្កាង ដើម្បីទូលអង្វរព្រះយេស៊ូតាមរយៈព្រះនាងម៉ារីសូមឲ្យព្រះអង្គការពារថែរក្សាយើងជានិច្ច។ នៅក្នុងភាពស្ងៀមស្ងាត់យប់នេះ ដែលព្រះយេស៊ូសោយទិវង្គតយើងដឹងថាព្រះយេស៊ូបានបំពេញបេសកកម្មរបស់ព្រះអង្គដ៏

ពេញលក្ខណៈ គឺប្រកាសព្រះរាជ្យរបស់ព្រះជាម្ចាស់។ យើងទាំងអស់គ្នា យើងថ្វាយបង្គំព្រះអង្គនៅក្បែរឈើឆ្កាងដោយគោរពឈើឆ្កាងរបស់ព្រះអង្គ ដើម្បីផ្ញើទុក្ខលំបាករបស់យើង ទុក្ខលំបាករបស់ប្រទេសយើង ទុក្ខលំបាករបស់ពិភពលោក ដែលកំពុងយំដោយសារមានអ្នកជំងឺនិងអ្នកស្លាប់ហួសពីការស្មាន។ យើងផ្ញើប្រទេសកម្ពុជារបស់យើង យើងផ្ញើអ្វីៗទាំងអស់ដែលបានជះឥទ្ធិពលអាក្រក់ទៅលើគ្រួសារ ទៅលើប្រជាជនដោយសារជំងឺកូវីដ១៩ យើងផ្ញើជីវិតរបស់យើងផ្ទាល់។ ដោយសារ យើងដឹងថាព្រះយេស៊ូគង់នៅជាមួយយើង យើងដឹងថាព្រះនាងម៉ារីកំពុងទូលអង្វរព្រះយេស៊ូសម្រាប់យើងទាំងអស់គ្នា។ នៅក្នុងភាពស្ងៀមស្ងាត់នៃដួងចិត្តរបស់យើង យើងនឹងថ្វាយបង្គំព្រះឈើឆ្កាងរបស់ព្រះគ្រីស្ត យើងគោរពឈើដែលព្រះយេស៊ូបានទទួលទុក្ខលំបាក យើងគោរពឈើដែលព្រះយេស៊ូបានប្រមូលអំពើបាបរបស់យើងទាំងអស់ បន្តិចម្តងៗយើងងើបមុខដើម្បីមើលព្រះភ័ក្ត្ររបស់ព្រះអង្គដែលកំពុងសម្លឹងមើលយើងដែរ។

ពីឈើឆ្កាង មានព្រះលោហិតនិងទឹកដែលហូរចេញពីព្រះបេះដូងរបស់ព្រះយេស៊ូ ដើម្បីប្រទានជំនឿរឹងមាំ ដើម្បីប្រទានសេចក្តីស្រឡាញ់ ដើម្បីប្រទានសេចក្តីសង្ឃឹមឲ្យយើង។ យប់នេះរហូតដល់ថ្ងៃស្អែក យើងចូលនៅក្នុងភាពស្ងៀមស្ងាត់របស់ព្រះជាម្ចាស់ ដើម្បីរួមគ្នាត្រៀមខ្លួនទទួលជីវិតថ្មីរួមជាមួយព្រះយេស៊ូ។ សូមបងប្អូនតាំងចិត្តអធិដ្ឋាន ដោយការពារថែរក្សាចិត្តស្មោះត្រង់ ការពារថែរក្សាសេចក្តីក្លាហាននៅក្នុងសេចក្តីស្រឡាញ់និងសេចក្តីសង្ឃឹម។ អាម៉ែន៕